**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ១៨៦២ សហវ.ប្រក

# ប្រកាស
## ស្តីពី
## ការបង្កើត អង្គភាពគ្រប់គ្រងសាច់ប្រាក់ ក្រោមឱវាទអគ្គលេខាធិការដ្ឋាន សំរាប់ជាសេនាធិការបច្ចេកទេស អោយ គ.ជ.ស នៃ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែកក្កដា ឆ្នាំ២០០៤ ដែលប្រកាសអោយប្រើច្បាប់រដ្ឋធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ

-បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករាឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញ ព្រះរាជក្រមលេខ ០១/នស/៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ហើយត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ១០/នស/៩៤ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ១៩៩៤ និងត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខនស/រកម/១២៩៩/១៥ ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ១៩៩៩ និងត្រូវបានកែប្រែដោយច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៦នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០២/០២០ ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២

-បានឃើញអនុក្រឹត្យលេខ០៤អនក្រ.បកចុះថ្ងៃទី ២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បកចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ២០០៤ ស្តីពីការបំពេញបន្ថែមនិងកែសម្រួលនាយកដ្ឋានមួយចំនួន នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-យោងតាមស្មារតីអង្គប្រជុំគណៈកម្មាធិការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone: 855-23-724 664 Fax: 855-23-427 798

## សំរេច

**ប្រការ១:** បង្កើតអង្គភាពគ្រប់គ្រងសាច់ប្រាក់ នៅក្នុងអគ្គលេខាធិការដ្ឋានក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុសំរាប់ជាលេខាធិការបច្ចេកទេស អោយគណៈកម្មការតាមដានការអនុវត្តថវិកា និងគ្រប់គ្រងសាច់ប្រាក់ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**ប្រការ២:** អង្គភាពគ្រប់គ្រងសាច់ប្រាក់ មានភារៈកិច្ចដូចតទៅ :

១. កសាងប្រព័ន្ធគ្រប់គ្រងសាច់ប្រាក់ ដោយសហការជាមួយនាយកដ្ឋានពាក់ព័ន្ធ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង អង្គភាពពាក់ព័ន្ធ នៃក្រសួងស្ថាប័ននានា ដែលអាចបង្ហាញបានជាប្រចាំនូវកម្មវិធីចំណូល ចំណាយនិងស្ថានភាពសាច់ប្រាក់រួមរបស់រាជរដ្ឋាភិបាល

២. តាមដាន និងព្យាករណ៍លំហូរចូល នៃចំណូលពីសារពើពន្ធ មិនមែនសារពើពន្ធ ការខ្ចី ប័ណ្ណរតនាគារ សញ្ញាប័ណ្ណរដ្ឋាភិបាល ។ ល ។

៣. តាមដានពិនិត្យចំណាយពិតប្រាកដនៃថវិកា និងការទូទាត់សាច់ប្រាក់របស់ក្រសួងស្ថាប័ន ខេត្ត-ក្រុង ខ័ណ្ឌ ឃុំ សង្កាត់ ព្រមទាំងពិនិត្យសមតុល្យសាច់ប្រាក់ ក្នុងគណនីទាំងឡាយ (រួមទាំងប្រាក់បុរេប្រទាន) ដែលគ្រប់គ្រងដោយប្រព័ន្ធរតនាគារជាតិ

៤. ធ្វើការបូកសរុប សំយោគ ដោយប្រៀបធៀបលំហូរចំណូល ស្ថានភាពសាច់ប្រាក់របស់រាជរដ្ឋាភិបាល ជាមួយនឹងកម្មវិធីចំណាយ ព្រមទាំង សេចក្តីត្រូវការសាច់ប្រាក់ តាមពេលវេលាជាក់ស្តែង ហើយលើកសំណើស្តីពី ការកំណត់ពិដាននៃការអនុវត្តថវិកា និងវិធានការធានារំដោះបន្ទុកសាច់ប្រាក់ ជូនក្រសួងស្ថាប័ននានា ។

៥. ផ្តល់អនុសាសន៍អំពីសេចក្តីត្រូវការ និងលទ្ធភាពដែលអាចបោះផ្សាយប័ណ្ណរតនាគារ ដើម្បីហិរញ្ញប្បទានបំពេញតម្រូវការសាច់ប្រាក់រយៈពេលខ្លី ។

**ប្រការ៣:** អង្គភាពគ្រប់គ្រងសាច់ប្រាក់ ដឹកនាំដោយ ប្រធានមួយរូបមានឋានៈស្មើអនុប្រធាននាយកដ្ឋាន និងមានអនុប្រធានមួយចំនួនជាជំនួយការ ។

**ប្រការ៤:** អគ្គលេខាធិការ នាយកខុទ្ទកាល័យ នាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធចំណុះក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះ អោយមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ,ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០០៧

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

គាត ឈន់

**ចម្លងជូន:**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួងរដ្ឋលេខាធិការដ្ឋាន- ស្ថាប័ន និងខេត្ត-ក្រុង "ដើម្បីជូនជ្រាប និងសហការអនុវត្ត"
- ដូចប្រការ ៤
- កាលប្បវត្តិ -ឯកសារ